# កម្រងសំនួរអំពី
# មូលនិធិដាំដុះ ឆ្នាំ២០២០

១. តើមូលនិធិដាំដុះចល័ត អាចប្រើសម្រាប់ការចូលរួមគម្រោង និវេសនដ្ឋាន (Residency) បានដែរឬទេ?

| |
|---|
| បាន។ |

២. តើមូលនិធិនេះ ផ្តល់ជូនប៉ុន្មាននាក់?

| |
|---|
| អាស្រ័យតាមទំហំថវិកាដែលយើងមាន។ |

៣. តើខ្ញុំអាចស្នើសុំទាំងមូលនិធិគម្រោង និងចល័តក្នុងពាក្យសុំតែមួយបានទេ?

| |
|---|
| មិនអាចស្នើសុំក្នុងពាក្យតែមួយបានទេ គឺអាចដាក់ស្នើដាច់ដោយឡែកពីគ្នា។ |

៤. តើខ្ញុំអាចស្នើសុំទៅអឺរ៉ុបបានទេ?

| |
|---|
| មិនបាន។ |

៥. តើមូលនិធិនេះ មានរយៈពេលមួយឆ្នាំឬ?

| |
|---|
| មែន។ |

៦. តើគណៈកម្មការ មានអ្នកជំនាញណាខ្លះ?

| |
|---|
| គណៈកម្មការនឹងត្រូវបានកំណត់តាមប្រភេទ និងទម្រង់ដែលបេក្ខជនបានស្នើសុំ |

**៧. តើមូលនិធិដាំដុះ មានប៉ុន្មានប្រភេទ? និងទឹកប្រាក់ចំនួនប៉ុន្មាន?**

មានពីរប្រភេទ៖ (១) សម្រាប់មូលនិធិចល័តរហូតដល់៥០០ ដុល្លារ និង (២) សម្រាប់មូលនិធិគម្រោងរហូតដល់ ២៥០០ ដុល្លារ។

**៨. ក្រោយពេលទទួលបានមូលនិធិ តើខ្ញុំត្រូវសរសេររបាយការណ៍ការងារ ឬត្រូវបង្ហាញសមិទ្ធផលបែបណា? តើខ្ញុំអាចនឹងត្រូវបង្ហាញការងារ ឬសមិទ្ធផលទាំងនោះទេ?**

ត្រូវអនុវត្តតាមគំរូរបាយការណ៍កំណត់ដោយសិល្បៈខ្មែរអមតៈ។ ពេលដាក់ស្នើសុំមូលនិធិ ត្រូវពិចារណាដល់លក្ខខណ្ឌនេះជាមុន។ យើងពុំមានករណីកិច្ចជួយរៀបចំក្នុងការងារនេះទេ តែយើងអាចផ្តល់ជំនួយខ្លះៗតាមការដែលអាចទៅរួច។

**៩. ប្រសិនបើខ្ញុំដំឡើង ឬបង្កើតស្នាដៃមួយ តើកម្មសិទ្ធិបញ្ញាជារបស់សិល្បៈខ្មែរអមតៈ ឬយ៉ាងណា? ប្រសិនបើខ្ញុំលក់ស្នាដៃនេះ តើខ្ញុំត្រូវប្រគល់ប្រាក់ជូនសិល្បៈខ្មែរអមតៈ ឬយ៉ាងណា?**

ជ័យលាភី ត្រូវរំលឹកពីសិល្បៈខ្មែរអមតៈក្នុងស្នាដៃទាំងនោះ។ ហើយយើងរីករាយនឹងទទួលកិច្ចបរិច្ចាគ / វិភាគទាន ជាសាគុណ ត្រឡប់វិញ។

**១០. តើខ្ញុំត្រូវធ្វើយ៉ាងណា ប្រសិនបើខ្ញុំចាយថវិកាមូលនិធិចល័តអស់ មុនពេលកំណត់?**

ប្រសិនបើអ្នកចាយលុយអស់មុនទៅចូលរួមកម្មវិធីដែលបានដាក់ស្នើសុំ អ្នកត្រូវបង់ត្រឡប់ចូលកម្មវិធីនោះវិញ។ ប្រសិនបើអ្នកចាយអស់ក្នុងពេលចូលរួមកម្មវិធី នោះចំណាយដែលកើតមានបន្តបន្ទាប់គឺជាខ្ទង់ចំណាយរបស់ជ័យលាភី។ ត្រូវចងចាំថា មូលនិធិនេះ គ្រាន់តែអាចជួយបំពេញបន្ថែមប៉ុណ្ណោះ។

**១១. តើខ្ញុំអាចដាក់ពាក្យស្នើសុំសម្រាប់គម្រោងពាក់ព័ន្ធនឹងគោលនយោបាយបានដែរឬទេ?**

បាន (កំណត់សម្គាល់៖ តើគោលនយោបាយនេះ សំដៅលើអ្វី? គោលបំណងនៃគម្រោង ក៏សំខាន់ដែរ)។

**១២. ក្នុងករណីដែលខ្ញុំបានទទួលមូលនិធិរួចហើយ ប៉ុន្តែខ្ញុំជួបនឹងបញ្ហា តើសិល្បៈខ្មែរអមតៈ នឹងអាចធ្វើអ្វីបាន? តើខ្ញុំនឹងទទួលបានជំនួយបន្ថែមដែរឬទេ?**

អាស្រ័យតាមភាពជាក់ស្តែង និងប្រភេទជំនួយស្នើសុំ។

**១៣. តើខ្ញុំអាចបញ្ចូលគម្រោងតូចៗចូលគ្នាបានដែរឬទេ?**

បាន ប៉ុន្តែត្រូវដាច់ដោយឡែកពីគ្នា។

**១៤. តើខ្ញុំត្រូវប្រគល់ទឹកប្រាក់ទៅវិញ ប្រសិនបើខ្ញុំមិនអាចបញ្ចប់គម្រោងនេះ ឬយ៉ាងណា?**

សម្រាប់មូលនិធិគម្រោង អ្នកត្រូវស្នើសុំផ្លាស់ប្តូរ និងត្រូវមានការឯកភាព ពីសិល្បៈខ្មែរអមតៈ។ សម្រាប់មូលនិធិចល័ត ប្រសិនបើអ្នកមិនអាចទៅចូលរួមកម្មវិធីដូចបានគ្រោងទុក អ្នកត្រូវប្រគល់ទឹកប្រាក់ជូនសិល្បៈខ្មែរអមតៈវិញ។

**១៥. តើប្រភេទគម្រោងការពារអភិរក្ស អាចដាក់ស្នើសុំមូលនិធិនេះបានទេ?**

បាន។

**១៦. តើគម្រោងដែលលើសពី ២៥០០ដុល្លារ អាចដាក់ស្នើសុំបានដែរឬទេ?**

អ្នកអាចសាកល្បងស្នើសុំបាន ប៉ុន្តែត្រូវចង់ចាំថា មូលនិធិនេះ គ្រាន់តែអាចជួយបន្ថែម។

**១៧. តើគម្រោងដែលក្រោម ៥០០ដុល្លារ អាចដាក់ស្នើសុំបានដែរឬទេ?**

បាន។

**១៨. តើមានមូលនិធិចល័ត/គម្រោងប៉ុន្មានដែលសិល្បៈខ្មែរអមតៈ ផ្តល់ជូនក្នុងមួយឆ្នាំៗ?**

អាស្រ័យតាមទំហំថវិកាដែលយើងមាន (សម្រាប់មូលនិធិគម្រោង អាចមានដល់ ៥កញ្ចប់។ សម្រាប់មូលនិធិចល័ត អាចមានដល់ ៦ កញ្ចប់។

**១៩. តើមានអ្វីកើតឡើងប្រសិនបើ ខ្ញុំចាយអស់លុយគម្រោងមុនពេលកំណត់?**

ប្រសិនបើអ្នកប្រើប្រាស់ទឹកប្រាក់អស់មុនពេលចូលរួមកម្មវិធី អ្នកត្រូវទូទាត់ទឹកប្រាក់ចូលកម្មវិធីវិញ។ ប្រសិនបើអ្នកប្រើប្រាស់ទឹកប្រាក់អស់ក្នុងកំឡុងពេលចូលរួមកម្មវិធី ខ្ទង់ចំណាយបន្ទាប់គឺជាបន្ទុករបស់អ្នក។ សូមចងចាំថា មូលនិធិនេះ គ្រាន់តែជួយបន្ថែមទឹកប្រាក់របស់អ្នកប៉ុណ្ណោះ។

២០. ប្រសិនបើគម្រោងវាធំជាងទឹកប្រាក់មូលនិធិ តើខ្ញុំអាចស្នើសុំមូលនិធិផ្សេងដើម្បីបង្គ្រប់បានដែរឬទេ? ឬ ឧទាហរណ៍ថា ខ្ញុំមានទឹកប្រាក់ខ្លះហើយ ប៉ុន្តែត្រូវការទឹកប្រាក់បន្ថែមពីមូលនិធិដើម្បីអាចដំណើរការគម្រោងបាន តើខ្ញុំអាចស្នើសុំមូលនិធិនេះដែរឬទេ?

| |
|---|
| បាន។ |

២១. នៅត្រង់ប្រអប់ សេចក្តីសង្ខេបគម្រោង ក្នុងពាក្យសុំ ប្រសិនបើខ្ញុំបានសង្ខេបហើយ ប៉ុន្តវានៅតែលើស ១ ឬ២ជួរ តើខ្ញុំអាចពង្រីកប្រអប់នោះបានដែរឬទេ?

| |
|---|
| បាន តែបើអាច សូមព្យាយាមធ្វើតាមលក្ខខណ្ឌ។ |

២២. តើខ្ញុំអាចព្រីនពាក្យស្នើសុំ ហើយបំពេញដោយដៃបានដែរឬទេ?

| |
|---|
| បាន។ |

២៣. តើសិល្បករអាចឲ្យអ្នកផ្សេងជួយសរសេរ ឬបំពេញពាក្យឲ្យបានដែរឬទេ?

| |
|---|
| បាន ប៉ុន្តែត្រូវតែជាគំនិតដើមរបស់អ្នកដាក់ស្នើសុំ។ |

២៤. ក្នុងករណីទៅចូលរួមកម្មវិធីផ្លាស់ប្តូរនៅក្រៅប្រទេស ហើយជាកម្មវិធីផ្លាស់ប្តូររវាងសិល្បករកម្ពុជា និងសិល្បករបរទេស តើខ្ញុំអាចស្នើសុំមូលនិធិនេះបានទេ? ក្នុងករណីថា កម្មវិធីផ្លាស់ប្តូរនេះ ធ្វើនៅកម្ពុជា តើខ្ញុំអាចស្នើសុំមូលនិធិនេះ សម្រាប់អញ្ជើញសិល្បករមកពីក្រៅប្រទេសបានដែរឬទេ?

| |
|---|
| សម្រាប់ សំនួរខាងដើម «បាន» តែសំនួរបន្ទាប់ «មិនបាន»។ |

២៥. តើគម្រោងដែលមានអាយុកាលលើសពីមួយឆ្នាំ អាចដាក់ស្នើសុំមូលនិធិនេះបានទេ?

| |
|---|
| មិនបាន។ |

២៦. ឧទាហរណ៍ថា គម្រោងមួយ មានច្រើនដំណាក់កាល ហើយត្រូវបញ្ចប់ក្នុងឆ្នាំផ្សេងៗគ្នា តើខ្ញុំអាចស្នើសុំមូលនិធិនេះសម្រាប់បញ្ចប់ដំណាក់កាលណាមួយ ដូចជាដំណាក់កាលទីមួយក្នុងឆ្នាំនេះ បានដែរឬទេ?

| |
|---|
| បាន។ |

២៧. តើខ្ញុំអាចស្នើសុំមូលនិធិនេះជាក្រុមបានដែរឬទេ?

| |
|---|
| បាន ប៉ុន្តែត្រូវមានអ្នកតំណាងម្នាក់។ |

២៨. ប្រសិនបើទីតាំងគម្រោងនៅកម្ពុជា ប៉ុន្តែត្រូវមានការធ្វើដំណើរក្រៅប្រទេសដើម្បីបញ្ចប់គម្រោងនេះ តើអាចប្រើមូលនិធិនេះបានទេ?

| |
|---|
| បាន។ |

២៩. តើខ្ញុំអាចស្នើសុំមូលនិធិនេះ សម្រាប់បើកថ្នាក់បង្ហាត់សិល្បៈស្បែកបានដែរឬទេ?

| |
|---|
| បាន។ |

៣០. តើខ្ញុំត្រូវធ្វើអ្វីខ្លះ បន្ទាន់ពីទទួលបានមូលនិធិនេះ? តើខ្ញុំត្រូវសរសេររបាយការណ៍ជាប់ជាប្រចាំឬទេ?

| |
|---|
| តាមលក្ខខណ្ឌរបស់សិល្បៈខ្មែរអមតៈ។ |